ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

អគ្គនាយកដ្ឋានយោធសេវា

# សាររំលែកទុក្ខ

## សូមគោរពជូន

## សម្តេចពិជ័យសេនា ទៀ បាញ់ និងលោកជំទាវ តៅ គឿន ទៀ បាញ់
## ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ

សម្តេចពិជ័យសេនា និងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

ឯកឧត្តម នាយឧត្តមសេនីយ៍ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិនិងលោកជំទាវ ជាទីគោរពដ៏ខ្ពង់ខ្ពស់!

តាងនាមថ្នាក់ដឹកនាំ នាយទាហាន នាយទាហានរងទាំងអស់ នៅក្នុងអគ្គនាយកដ្ឋានយោធសេវា នៃក្រសួងការពារជាតិ ក្នុងនាមខ្ញុំនិងភរិយា ព្រមទាំងក្រុមគ្រួសារ មានសេចក្តីក្រៀមក្រំជាទីបំផុត ប្រកបដោយសមានទុក្ខនិងក្តុកក្តួលចិត្តឥតឧបមា ដោយបានទទួលព័ត៌មានអំពីមរណភាពរបស់ មហាឧបាសិកា យិប ថាំកេសន ដែលត្រូវជា ម្តាយបង្កើត ម្តាយក្មេក ជីដូន និងជីទួត បានទទួលមរណភាព នៅថ្ងៃចន្ទ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង ១២:២០នាទីរសៀល ក្នុងជន្មាយុ ៩៩ឆ្នាំ ដោយរោគាពាធ។

យើងខ្ញុំទាំងអស់គ្នា សូមចូលរួមរំលែកទុក្ខជាមួយ សម្តេច លោកជំទាវ ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ចំពោះការបាត់បង់ មហាឧបាសិកា យិប ថាំកេសន ជាម្តាយបង្កើត ម្តាយក្មេក ជីដូន និងជីទួត ជាទីគោរពស្រឡាញ់ ប្រកបដោយព្រហ្មវិហារធម៌ ដ៏ជ្រាលជ្រៅចំពោះកូនៗ ចៅៗទាំងអស់ ដែលកន្លងមកក្នុងមួយជីវិតរបស់ មហាឧបាសិកា តែងបានខិតខំចិញ្ចឹមបីបាច់ថែរក្សា និងអប់រំទូន្មានបុត្រធីតា និងចៅៗ ប្រកបដោយទឹកចិត្តសណ្តោសប្រណីដ៏ថ្លៃថ្លា រហូតក្លាយជាបញ្ញវន្ត ជាថ្នាក់ដឹកនាំនិងជាធនធានមនុស្សដ៏មានតម្លៃ មានគុណធម៌ និងភាពជាអ្នកដឹកនាំសម្រាប់សង្គមជាតិកម្ពុជា។

ក្នុងឱកាសប្រកបដោយសមានទុក្ខក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នាសូមឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ មហាឧបាសិកា យិប ថាំកេសន បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចពិជ័យសេនា ទៀ បាញ់ និងលោកជំទាវ តៅ គឿន ទៀ បាញ់ ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា និងលោកជំទាវ ព្រមទាំងក្រុមគ្រួសារ** ទទួលនូវមនោសញ្ចេតនាគោរពស្រឡាញ់ កក្តីភាពដ៏ខ្ពង់ខ្ពស់បំផុត និងសូមចូលរួមរំលែកទុក្ខដោយក្តីក្រៀមក្រំ សោកស្តាយ អាឡោះអាល័យយ៉ាងក្រៃលែងពីយើងខ្ញុំទាំងអស់គ្នា។

ថ្ងៃចន្ទ ៨កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣

**អគ្គនាយក**

នាយឧត្តមសេនីយ៍ **មាស សាម៉ន**